00543809

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 01/07/2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

D356/2/9

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៦៦) |
| ចំពោះមុខ៖ | ចៅក្រម ប្រាក់ គឹមសាន ប្រធាន |
| | ចៅក្រម Rowan DOWNING |
| | ចៅក្រម នេយ ថុល |
| | ចៅក្រម Catherine MARCHI-UHEL |
| | ចៅក្រម ហួត វុទ្ធី |
| កាលបរិច្ឆេទ៖ | ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១០ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 01/07/2010
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សាធារណៈ: (កោសលុប)

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធលើសំណើសុំយោបល់ពីអ្នកជំនាញជាលើកទីពីរ**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ជនត្រូវចោទ**

លោក នួន ជា

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោក នី ច័ន្ទឌី

លោក Mahdev MOHAN

កញ្ញា Lima NGUYEN

លោក គឹម ម៉េងឃី

**សហមេធាវីការពារក្តីជនត្រូវចោទ**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី Elizabeth-Joelle RABESANRATANA

លោកស្រី Annie DELAHAIE

លោក Philippe CANONNE

លោកស្រី Martine JACQUIN

លោកស្រី Fabienne TRUSSES-NAPROUS

លោកស្រី Françoise GAUTRY

លោកស្រី Isabelle DURAND

លោកស្រី Christine MARTINEAU

លោកស្រី Laure DESFORGES

លោក Ferdinand DJAMMEN-NZEPA

លោក ឡោ ជុនធី

លោកស្រី ស៊ីន សុវ៉ន

លោក សំ សុគង់

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក គង់ ហេង

លោកស្រី Silke STUDZINSKY

លោក Olivier BAHOUGNE

លោកស្រី Marie GUIRAUD

លោក Partirck BAUDOUIN

លោកស្រី ជេត វណ្ណលី

លោក ពេជ អង្គ

លោក Julien RIVET

លោក Pascal AUBOIN

លោក យ៉ុង ផានិត

**<u>ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង</u>**

**<u>សហចៅក្រមស៊ើបអង្កេត</u>**

លោក យូ ប៊ុន ឡេង

លោក Marcel LEMONDE

00543811



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍ របស់លោក នួន ជា ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធលើសំណើសុំយោបល់ពីអ្នកជំនាញជាលើកទីពីរ" ដែលសហមេធាវីការពារក្តីរបស់លោក នួន ជា ("ជនត្រូវចោទ") បាន ដាក់កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ("បណ្តឹងឧទ្ធរណ៍")[១]។

## **ប្រវត្តិ**

១. កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០០៨ សហមេធាវីការពារក្តីរបស់លោក នួន ជា បានដាក់ "សំណើទីប្រាំមួយសុំឱ្យបំពេញកិច្ចស៊ើបសួរ" ("សំណើទី៦") ជូនសហចៅក្រមស៊ើបអង្កេត[២]។ សំណើទី៦ របស់លោក នួន ជា បានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ខិតខំប្រឹងប្រែងកំណត់ពី [redacted] ដោយមានជំនួយពីអ្នកជំនាញ [redacted] ដែលមានសមត្ថភាពមួយរូប (ឬអ្នកជំនាញច្រើនរូប)[៣]។ លើសពីនេះទៅទៀត សំណើសុំនេះបានស្នើសុំឱ្យចាត់តាំងអ្នកជំនាញបែបនេះមួយរូប ឬច្រើនរូបបន្ថែមទៀត[៤]។

២. នៅថ្ងៃទី១០ ខែមីនា ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេតបានឆ្លើយតបជាវិជ្ជមានទៅនឹងសំណើទី៦ របស់លោក នួនជា[៥] ហើយបានតែងតាំងបណ្ឌិត អេវ៉ា ម៉ារីយ៉ា តាបូ (Ewa Maria Tabeau) និងលោក ថី ឃាម (They Kheam) ឱ្យធ្វើជាអ្នកជំនាញ [redacted] ដើម្បីដាក់ជូនរបាយការណ៍នៅត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ("ដីកាចាត់តាំងអ្នកជំនាញ")[៦] ។ នៅថ្ងៃទី២៨ ខែ

---

[១] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំយោបល់ពីអ្នកជំនាញជាលើកទីពីរ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០១០, ឯកសារ D356/2/1។

[២] សំណើទីប្រាំមួយសុំឱ្យបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១០, ឯកសារ D311។

[៣] សំណើទី៦ របស់លោក នួន ជា, កថាខណ្ឌ៩។

[៤] សំណើទី៦ របស់លោក នួន ជា, កថាខណ្ឌ១។

[៥] ចម្លើយតបទៅនឹងសំណើទី៦ សុំឱ្យបំពេញកិច្ចស៊ើបសួរ (D311) និងចម្លើយតបដោយផ្នែក ទៅនឹងសំណើទី៥ សុំឱ្យបំពេញកិច្ចស៊ើបសួរ (D105), ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ ឯកសារ D311/2 និង D105/2។

[៦] ដីកាចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩, ឯកសារ D104។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

មេសា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានពន្យារកាលបរិច្ឆេទកំណត់សម្រាប់ការដាក់របាយការណ៍នេះ រហូតទៅដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩[៧]។

៣. នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ បណ្ឌិត Ewa Maria Tabeau និងលោក ធី ឃាម បានដាក់ជូនរបាយការណ៍អ្នកជំនាញ[redacted]របស់ពួកគាត់រួមគ្នា ("របាយការណ៍អ្នកជំនាញ")[៨]។

៤. នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ សហមេធាវីការពារក្ដីរបស់ជនត្រូវចោទបានដាក់សំណើលើកទីម្ភៃប្រាំមួយរបស់លោក នួន ជា ស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ ("សំណើទី២៦")[៩] ដោយស្នើសុំឲ្យមាន "ការចាត់តាំងអ្នកជំនាញមួយរូបបន្ថែមទៀត ដើម្បីត្រួតពិនិត្យមើលកម្មវត្ថុដែលមាននៅក្នុងរបាយការណ៍អ្នកជំនាញ[redacted]នេះឡើងវិញ"[១០] ដោយសារសហមេធាវីការពារក្ដីអះអាងថា របាយការណ៍អ្នកជំនាញនេះ "មិនសូវមាន[តម្លៃ]ដោយមានភាពមិនប្រក្រតីដែលមិនចាំបាច់ និងមានកំហុសឆ្គងជាច្រើន ព្រមទាំងបានបង្ហាញពីភាពស្មាក់ស្មើរក្នុងការស្វែងរកភស្តុតាងដោះបន្ទុក និងកង្វះខាតអនាគតិភាព"[១១]។ សហមេធាវីការពារក្ដីបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត៖ ១) ចាត់តាំងអ្នកជំនាញ[redacted]មួយរូបទៀត ដែលមានចំណេះដឹងខាង[redacted] ដើម្បីវាយតម្លៃឡើងវិញពីចំនួនអ្នកស្លាប់សន្មតថា [redacted] ២) ធ្វើការស៊ើបអង្កេតទាក់ទងនឹងការដែលបណ្ឌិត Ewa Tabeau អនុវត្តភាពលំអៀងខាងចោទប្រកាន់ ៣) លាតត្រដាងពីការឆ្លើយឆ្លងណាមួយ ឬទាំងអស់រវាងបណ្ឌិត Ewa Tabeau និងសហចៅក្រមស៊ើបអង្កេត (ស.ច.ស) ឬការិយាល័យសហព្រះរាជអាជ្ញា (ក.ស.ព) ៤) [បង្ហាញឯកសារយោងដែលអ្នកជំនាញបានយកមកធ្វើជាសំអាង] ៥) បង្ហាញអត្តសញ្ញាណ

---

[៧] កំណែនៃដីកាចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩, ឯកសារ D104/1។

[៨] របាយការណ៍អ្នជំនាញ[redacted], ជនរងគ្រោះនៃរបបខ្មែរក្រហមនៅកម្ពុជា ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩, ការវាយតម្លៃស៊ីជម្រៅលើការប៉ាន់ប្រមាណសំខាន់ៗ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩, ឯកសារ D104/1/1។

[៩] សំណើលើកទីម្ភៃប្រាំមួយ ស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០, ឯកសារ D356។

[១០] សំណើទី២៦, កថាខណ្ឌ១។

[១១] សំណើទី២៦, កថាខណ្ឌ១១។

និងផ្តល់សម្ភារៈដែល ស.ច.ស បានផ្តល់ឱ្យអ្នកជំនាញ ៦) ផ្តល់នូវការរាប់ចំនួនអ្នកស្លាប់ពិតប្រាកដដោយអ្នកជំនាញដើម្បីទទួលបាន "ចំនួនទិន្នន័យដែលអាចទទួលយកបានតាមបែប[redacted]"[១២]។

៥. នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបដិសេធសំណើទីម្ភៃប្រាំមួយ ("ដីកាសម្រេច")[១៣]។ នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១០ សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានដាក់ការជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ ហើយនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ សហមេធាវីការពារក្តីបានដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះ។

៦. នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានកំណត់កាលបរិច្ឆេទបើកសវនាការទៅលើបណ្តឹងឧទ្ធរណ៍ដែលត្រូវប្រារព្ធធ្វើនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ "ភ្ជាប់ដោយលក្ខខណ្ឌស្តីពីការដែលអង្គបុរេជំនុំជម្រះ ទទួលបានការជូនដំណឹងពីចេតនាដាក់ជូនសេចក្តីសន្និដ្ឋានផ្ទាល់មាត់ពីអ្នកឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍"[១៤]។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់ការជូនដំណឹងដោយបញ្ជាក់ថា "ខ្លួនមិនមានចេតនាដាក់ជូនសេចក្តីសន្និដ្ឋានឆ្លើយតបជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ណាមួយ" ទៅនឹងបណ្តឹងឧទ្ធរណ៍នេះទេ[១៥]។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់ជូនអ្វីទាំងអស់នៅក្នុងអំឡុងកាលបរិច្ឆេទកំណត់នេះ។ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានលុបចោលសវនាការទៅលើបណ្តឹងឧទ្ធរណ៍នេះ ដោយសម្រេចពិចារណាទៅលើបញ្ហានេះ ដោយផ្អែកតែទៅលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ

---

[១២] សំណើទី២៦, កថាខណ្ឌ៣៧។

[១៣] ដីកាសម្រេចបដិសេធលើសំណើសុំយោបល់ពីអ្នកជំនាញជាលើកទីពីរ (សំណើលើកទីម្ភៃប្រាំមួយរបស់ នួន ជា សុំឱ្យធ្វើកិច្ចស៊ើបសួរ) ចុះថ្ងៃទី១ ខែមេសា ឆ្នាំ ២០១០, ឯកសារ D356/1។

[១៤] ដីកាកំណត់កាលបរិច្ឆេទបើកសវនាការ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០១០, ឯកសារ D356/2/2។

[១៥] ការដកមកវិញនូវសេចក្តីជូនដំណឹងអំពីការចូលរួមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០១០, ឯកសារ D356/2/6។

00543814



សម្រាប់បណ្តឹងឧទ្ធរណ៍នេះប៉ុណ្ណោះ[១៦]។

៧. នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានប្រកាសជាលាយលក្ខណ៍អក្សរអំពីការសម្រេចដោះស្រាយជាចុងក្រោយរបស់ខ្លួនទៅលើបណ្តឹងឧទ្ធរណ៍ ដោយបញ្ជាក់ថា "សាលដីកាមានសំអាងហេតុទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នេះ នឹងប្រកាសក្នុងពេលមួយសមស្រប"។

**អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទថាៈ**

១. "ទទួលយកបណ្តឹងឧទ្ធរណ៍នេះ តែត្រង់សំណើសុំចាត់តាំងអ្នកជំនាញមួយរូបបន្ថែមទៀត ដើម្បីធ្វើការពិនិត្យឡើងវិញលើរបាយការណ៍អ្នកជំនាញដែលមានស្រាប់ ប៉ុន្តែ មិនទទួលយកសំណើសុំដទៃទៀតឡើយ។

២. បដិសេធចោលសំណើសុំដែលទទួលយកបានក្នុងបណ្តឹងឧទ្ធរណ៍ ទុកជាឥតបានការទៅលើអង្គសេចក្តី"[១៧]។

៨. អង្គបុរេជំនុំជម្រះសូមផ្តល់សំអាងហេតុខាងក្រោមសម្រាប់សាលដីកានេះ។

## សំអាងហេតុនៃសេចក្តីសម្រេច

### ក. ច្បាប់ពាក់ព័ន្ធ

៩. យោងតាមវិធាន៣១, ៥៥, ៧៣, ៧៤ និង ៧៥ នៃវិធានផ្ទៃក្នុង។

### ខ. ភាពអាចទទួលយកបាន

១០. នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេច និងបានជូនដំណឹង

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

---

[១៦] ដីកាសម្រេចលុបចោលសវនាការ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០១០, ឯកសារ D356/2/7។

[១៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស បដិសេធលើសំណើសុំយោបល់ពីអ្នកជំនាញជាលើកទីពីរ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០១០, ឯកសារ D356/2/8។

00543815



ដល់ជនត្រូវចោទ នៅថ្ងៃដដែលនេះ។ នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១០ សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានដាក់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍។ សារណាទៅលើបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ជូននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌពេលកំណត់ដែលមានចែងក្នុងវិធាន៧៥(៣) នៃវិធានផ្ទៃក្នុង។

១១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ជូន ដោយអនុលោមតាមវិធាន៧៣, ៧៤ និង ៧៥ នៃវិធានផ្ទៃក្នុង[១៨] និងបានយោងទៅលើសំណើនានាដែលសហមេធាវីការពារក្តីបានដាក់ជូនទៅសហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន៥៥(១០) និង ៣១(១០) នៃវិធានផ្ទៃក្នុង[១៩]។

១២. ដោយសារបណ្តឹងឧទ្ធរណ៍នេះជាប់ទាក់ទងនឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្តីយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន ព្រោះថា៖

> "តាមរយៈដីកានោះ វាច្បាស់ណាស់ថា សហចៅក្រមស៊ើបអង្កេត៖ (១) បានទទួលស្គាល់ថា សំណើទី២៦ ត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវស្របតាមវិធានផ្ទៃក្នុង និង (២) បានច្រានចោលសំណើនេះទៅលើអង្គសេចក្តី។ ដូច្នេះ អនុលោមតាមវិធាន៧៤(៣)(ខ)នៃវិធានផ្ទៃក្នុង បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន"[២០]។

១៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ចំពោះផ្នែកនោះនៃសំណើទីម្ភៃប្រាំមួយដែលបានដាក់ស្រប

---

[១៨] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ១។

[១៩] សំណើទី២៦, កថាខណ្ឌ១ ដែលយោងទៅលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ និងអនុលោមតាមវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង និងសំណើសុំឱ្យចាត់តាំងអ្នកជំនាញមួយរូបបន្ថែមទៀត ដើម្បីពិនិត្យមើលរបាយការណ៍អ្នកជំនាញឡើងវិញ ដោយអនុលោមតាមវិធាន៣១(១០) នៃវិធានផ្ទៃក្នុង។

[២០] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ១៣។

00543816



តាមវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង ដីកាសម្រេចមិនបានពិចារណាឱ្យបានច្បាស់លាស់អំពីបញ្ហានៃភាពទទួលយកបានទេ។ ក្នុងសំណើទីម្ភៃប្រាំមួយ សហមេធាវីការពារក្តីលើកឡើងជូនសហចៅក្រមស៊ើបអង្កេតនូវសំណើបន្ទាប់បន្សំមួយចំនួន[២១]។ សំណើទីម្ភៃប្រាំមួយមិនបានពន្យល់ថាតើសំណើបន្ទាប់សន្សំណាខ្លះនៃសំណើសុំនេះត្រូវបានដាក់ជូនដោយអនុលោមតាមវិធាន៥៥(១០) និងស្របតាមវិធាន៣១(១០) នៃវិធានផ្ទៃក្នុង។

១៤. ដោយពិចារណាទៅលើខ្លឹមសារនៃសំណើបន្ទាប់បន្សំខ្លះ ដែលមិនជាប់ទាក់ទងដោយផ្ទាល់ទៅនឹងវិធាន៣១(១០)[២២] នៃវិធានផ្ទៃក្នុង នោះអង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សំណើបន្ទាប់បន្សំទាំងនេះក៏មិនឋិតនៅក្រោមវិធាន៥៥(១០) នៃវិធានផ្ទៃក្នុងដែរ ដោយសារសំណើបន្ទាប់បន្សំទាំងនេះមិនស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរដែលឋិតនៅក្នុងវិធាន៥៥(១) ប៉ុន្តែវាហាក់ដូចជាការព្យាយាមច្រើនមុខរបស់មេធាវីការពារក្តី ដើម្បីត្រៀមរៀបចំការសួរតទល់គ្នាតែប៉ុណ្ណោះ។ អនុលោមតាមវិធាន៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ដើម្បីឱ្យបណ្តឹងឧទ្ធរណ៍មួយអាចទទួលយកបាននោះត្រូវបំពេញបុរេលក្ខខណ្ឌពីរ៖ ទីមួយ ត្រូវមានសំណើសុំមួយដែល "អនុញ្ញាតដោយវិធានផ្ទៃក្នុង" និងទីពីរ សំណើសុំបែបនេះត្រូវបានសហចៅក្រមស៊ើបអង្កេត "បដិសេធចោល"[២៣]។ ក្នុងករណីនេះ សំណើសុំបន្ទាប់បន្សំដែលបានលើកឡើងក្នុងកថាខណ្ឌ ៣៧(ខ) និង(គ) នៃសំណើទីម្ភៃប្រាំមួយ មិនត្រូវបានចាត់ទុកថា មានលក្ខណៈសម្បត្តិជាសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ "ដែលត្រូវបានអនុញ្ញាតដោយវិធានផ្ទៃក្នុងនោះទេ"។ អាស្រ័យហេតុនេះ សំណើសុំបន្ទាប់សន្សំមិនបានផ្តល់ហេតុផលណាមួយ ដើម្បីឱ្យវិធាន៧៤(៣)(ខ) នៃវិធានផ្ទៃក្នុងអាចអនុវត្តទៅបាននោះទេ។

១៥. ទាក់ទងទៅនឹងចំណុចសេសសល់ផ្សេងទៀតនៃបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះយល់ឃើញថា "វិធានផ្ទៃក្នុងអនុញ្ញាតឱ្យមេធាវីការពារក្តីស្នើសុំឱ្យមានការចាត់តាំងអ្នកជំនាញ ដើម្បីពិនិត្យមើល

---

[២១] សំណើទី២៦, កថាខណ្ឌ៣៧ និងសូមមើលកថាខណ្ឌ៤ ខាងលើនេះផងដែរ។

[២២] សំណើទី២៦, កថាខណ្ឌ៣៧(ខ) និង(គ)។

[២៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើលើកទី១១ របស់... ស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩, ឯកសារ D158/5/1, កថាខណ្ឌ២១ និង២៤។

អង្គបុរេជំនុំជម្រះ ... * PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

00543817



បញ្ហាដែលជាកម្មវត្ថុនៃរបាយការណ៍អ្នកជំនាញដែលមានស្រាប់នេះឡើងវិញ”[២៤]។

## គ. បទដ្ឋាននៃការពិនិត្យឡើងវិញ

១៦. បណ្តឹងឧទ្ធរណ៍នេះទាក់ទងទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើរបស់សហមេធាវីការពារក្តីសុំឱ្យចាត់តាំងអ្នកជំនាញមួយរូបបន្ថែមទៀត ដើម្បីពិនិត្យមើលរបាយការណ៍ដែលមានស្រាប់ឡើងវិញ និងចោទប្រកាន់ថា “ដីកាសម្រេចនេះ គឺមិនមានយុត្តិធម៌ និងមិនមានហេតុផលទាល់តែសោះ ដែលបង្កើតបានជាការរំលោភបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត”[២៥]។ សហមេធាវីការពារក្តីរបស់ជនត្រូវចោទ មិនបានដាក់ជូនអ្វីដែលជាប់ទាក់ទងទៅនឹងបទដ្ឋាននៃការពិនិត្យមើលដែលអាចអនុវត្តបានចំពោះវិការៈនានា ដូចជា កំហុសដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។

១៧. វិធានផ្ទៃក្នុងមិនមានចែងអំពីបទដ្ឋាននៃការពិនិត្យមើល សម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំនានាដែលភាគីទាំងឡាយបានដាក់ជូនស្របតាមវិធាន៥៥(១០) និង៣១(១០) នៃវិធានផ្ទៃក្នុងនោះទេ។ សំណើសុំទាំងឡាយដែលភាគីនានាបានដាក់ស្របតាមវិធាន៣១(១០) នៃវិធានផ្ទៃក្នុង ដូចជា សំណើសុំដែលបានដាក់ស្របតាមវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង មានគោលបំណងស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬចាត់វិធានការណាមួយដែលសហចៅក្រមស៊ើបអង្កេតយល់ថាចាំបាច់សម្រាប់បំពេញកិច្ចស៊ើបសួរនោះ។ នៅក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំឱ្យស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (“សាលដីកាលើSMD”)[២៦] អង្គបុរេជំនុំជម្រះ តាមរយៈការស្វែងរកគោលការណ៍ណែនាំនៅក្នុងយុត្តិសាស្ត្រនៃ

---

[២៤] បណ្តឹងឧទ្ធរណ៍ ផ្នែក V/B។

[២៥] សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំឱ្យចាត់តាំងអ្នកជំនាញបន្ថែមទៀត ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២00៩, ឯកសារ D140/4/5, កថាខណ្ឌ២២។

[២៦] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ សចស លើសំណើសុំឱ្យស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២00៩, ឯកសារ D164/4/13, កថាខណ្ឌ២២ ដល់ ២៧។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

តុលាការអន្តរជាតិនានាយល់ឃើញថា ការពិនិត្យទៅលើដីកាសម្រេចបែបនេះ គឺកំណត់យកត្រឹមការកំណត់ថាតើសហចៅក្រមស៊ើបអង្កេត បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវដែរឬអត់នោះ ដោយអនុវត្តបទដ្ឋាន (Test) ដែលបានកំណត់នៅក្នុង "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការចាត់តាំងមេធាវីការពារក្តី" ក្នុងរឿងក្តី *Milosevic* ***តទល់នឹង រដ្ឋអាជ្ញា*** ("សាលដីកាលើរឿងក្តី Milosevic")[២៧] ដែលចេញដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY")។ បទដ្ឋាននៅក្នុងសាលដីកាលើរឿងក្តី Milosevic កំណត់ថា៖

> "ការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវកែប្រែ ប្រសិនបើសេចក្តីសម្រេចដែលរងការជំទាស់នេះ (១) បានសំអាងទៅលើការបកស្រាយច្បាប់ជាធរមានមិនបានត្រឹមត្រូវនោះទេ (២) បានសំអាងទៅលើសេចក្តីសន្និដ្ឋានអំពីអង្គហេតុដែលមិនត្រឹមត្រូវទាល់តែសោះនោះ ឬ (៣) មិនមានយុត្តិធម៌ ឬមិនមានហេតុផលទាល់តែសោះ ដែលបង្កើតបានជាការរំលោភបំពានឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។ ដូច្នេះ ការមិនមានកំហុសអង្គច្បាប់ ឬមិនមានការភាន់ច្រឡំអង្គហេតុនាំឱ្យមានវិសាលភាពតិចតួចក្នុងការប្តឹងឧទ្ធរណ៍ បើទោះជាអង្គជំនុំជម្រះសាលាឧទ្ធរណ៍យល់ថា មិនគួរបង្ខំឱ្យមានមេធាវីការពារលោក Milosevic ក៏ដោយ ។ សាលក្រមខាងក្រោមនេះនឹងត្រូវបានតម្កល់ទុក លើកលែងតែសេចក្តីសម្រេចនេះមិនមានហេតុផលទាល់តែសោះដែលនាំឱ្យមានការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមានហេតុផលនោះទេ"[២៨] ។

១៨. គោលការណ៍ណែនាំបន្ថែមពីយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិជាច្រើនបង្ហាញថា បទដ្ឋានដូចគ្នានេះត្រូវបានយកមកអនុវត្ត នៅពេលធ្វើការពិនិត្យមើលទៅលើបណ្តឹងឧទ្ធរណ៍ទាំងឡាយទាក់ទងនឹងដីកាសម្រេចលើសំណើសុំដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងសំណើសុំនានា ដែល

---

[២៧] រឿងក្តី *Milosevic* ***តទល់នឹង រដ្ឋអាជ្ញា,*** IT 02-54-AR73.7, "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការចាត់តាំងមេធាវីការពារក្តី" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ ២០០៤។

[២៨] សាលដីកាលើរឿងក្តី *Milosevic* កថាខណ្ឌ៩ ដល់ ១០ (លេខយោងជើងទំព័រត្រូវបានលុបចោល)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

បានដាក់ជូន ស្របតាមវិធាន៣១(១០) នៃវិធានផ្ទៃក្នុង[២៩]។

## ឃ. ការពិចារណា

១៩. សហមេធាវីការពារក្តីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានកំហុសដោយសារពួកគាត់មិនបានចាត់តាំង និងណែនាំឱ្យអ្នកជំនាញមានសមត្ថភាពព្យាយាមប្រមូលភស្តុតាង[redacted] ដើម ហើយការដែលសហចៅក្រមស៊ើបអង្កេតមិនបានប្រមូលទិន្នន័យបែបនេះ គឺជាការបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន[៣០]។

២០. នៅក្នុងសំណើទីម្ភៃប្រាំមួយ សហមេធាវីការពារក្តីបានស្នើសុំឱ្យចាត់តាំងអ្នកជំនាញ[redacted]មួយរូបទៀត ដែលមានចំណេះដឹងខាង[redacted] ដើម្បីវាយតម្លៃឡើងវិញពី[redacted]"[៣១]។

២១. នៅក្នុងដីការបស់ខ្លួន សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា សហមេធាវីការពារក្តីមិនបានស្នើសុំអ្នកជំនាញ[redacted]ទេ គឺគ្រាន់តែសុំអ្នកជំនាញខាង[redacted]ម្នាក់ប៉ុណ្ណោះ ហើយថាសំណើទីម្ភៃប្រាំមួយរបស់សហមេធាវីដែល "សុំឱ្យចាត់តាំងអ្នកជំនាញ[redacted]មួយរូបទៀតដែលមានប្រវត្តិការងារខាងនីតិបច្ចេកវិទ្យា ដើម្បីធ្វើការស្រាវជ្រាវជាថ្មី និងកំណត់ទិន្នន័យឱ្យបានត្រឹមត្រូវ" ត្រូវបានដាក់មកយឺតពេលពេក ព្រមទាំងបណ្តាលឱ្យមានការពន្យារពេលច្រើនដល់ដំណើរការនីតិវិធី ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទ[៣២]។

---

[២៩] *រដ្ឋអាជ្ញា តទល់នឹង Vujadin Popovic និងអ្នកដទៃទៀត*, IT-05-88-AR73.2, "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្រួមគ្នារបស់មេធាវីការពារក្តី ទាក់ទងទៅនឹងឋានៈរបស់ Richard Butler ក្នុងនាមជាសាក្សីជំនាញ", អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៨។

[៣០] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ១៤។

[៣១] សំណើទី២៦, កថាខណ្ឌ៣៧(ក)។

[៣២] ដីកាសម្រេច, កថាខណ្ឌ៧។

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

២២. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការតវ៉ារបស់សហមេធាវីការពារក្តីទៅលើវិធីប្រមូលភស្តុតាង ឬវិធីនៃការបង្គាប់ឲ្យប្រមូលភស្តុតាង គឺគ្រាន់តែជាការអះអាងតែប៉ុណ្ណោះ មិនមែនជាការបង្ហាញពីកំហុសឆ្គង ឬការបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតនោះទេ[៣៣]។ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីការពារក្តីបានជំទាស់តវ៉ាថា អ្នកជំនាញដែលត្រូវបានចាត់តាំងមិនបានអនុវត្តការស្រាវជ្រាវ[redacted]ដើមទេ។ ត្រង់ចំណុចនេះ សហមេធាវីការពារក្តីបានព្យាយាមបកស្រាយសំណើសុំរបស់ខ្លួន ដើម្បីបង្ហាញថាខ្លួនពិតជាមានបំណងស្នើសុំឲ្យ "ប្រមូលភស្តុតាង[redacted]ដែលអាចជឿជាក់បាន ក្នុងដំណាក់កាលនៃការស៊ើបអង្កេត"[៣៤]។

២៣. អង្គបុរេជំនុំជម្រះក៏សង្កេតឃើញផងដែរថា សំណើទីម្ភៃប្រាំមួយដើម មិនបានស្នើសុំឲ្យចាត់តាំងអ្នកជំនាញ[redacted] ឬសុំឲ្យប្រមូលទិន្នន័យ[redacted]ដើមជាក់លាក់ឡើយ ហើយដីកាសម្រេចចាត់តាំងរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានជូនដំណឹងទៅសហមេធាវីការពារក្តីនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩[៣៥]។ ប្រសិនបើសហមេធាវីការពារក្តីមិនពេញចិត្តនឹងវិធីបកស្រាយ ឬការសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើទីម្ភៃប្រាំមួយរបស់ខ្លួនក្នុងដីកាសម្រេចចាត់តាំងអ្នកជំនាញនៅពេលនោះទេ សហមេធាវីការពារក្តីមានជំរើសក្នុងការពន្យល់បន្ថែម ឬពន្យល់ឲ្យបានច្បាស់ជូនសហចៅក្រមស៊ើបអង្កេត អំពីគោលបំណងពិតប្រាកដនៃសំណើទីម្ភៃប្រាំមួយរបស់ខ្លួន ឬធ្វើសំណើយ៉ាងជាក់លាក់ឲ្យ[៣៦]សហចៅក្រមស៊ើបអង្កេតចាត់តាំងអ្នកជំនាញ[redacted]បន្ថែម ដើម្បីធ្វើការត្រួតពិនិត្យ[redacted]ជាថ្មីឡើងវិញ ដោយអនុលោមទៅតាមវិធាន ៣១(១០) នៃវិធានផ្ទៃក្នុង។ នៅពេលនោះ សហមេធាវីការពារក្តីបានសម្រេចមិន

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

[៣៣] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ១៤ ដល់ ១៧។

[៣៤] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ១៤។

[៣៥] ដីកាចាត់តាំងអ្នកជំនាញ[redacted] ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩, ឯកសារ D140។

[៣៦] អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា គ្មានសំណើសុំណាមួយ ក្នុងចំណោមសំណើសុំទាំងអស់របស់ជនត្រូវចោទ ស្តីពីបញ្ហានេះមានភាពជាក់លាក់គ្រប់គ្រាន់ ក្នុងការដែលពួកគេចង់បានការចាត់តាំងអ្នកជំនាញ[redacted]នោះទេ។ មេធាវីការពារក្តីគួរតែដាក់សំណើសុំអ្នកជំនាញ[redacted] នៅក្នុងសេចក្តីសន្និដ្ឋាននៃសំណើសុំ។

ប្រើឱកាសនេះទេ ហើយមិនអាចប្រើឱកាសនេះបន្ទាប់ពីរយៈពេលជិតមួយឆ្នាំក្រោយមក ដើម្បីតវ៉ាតាមរយៈការដាក់សំណើសុំថ្មីថា របាយការណ៍ពីអ្នកជំនាញ[redacted]មាន "វិធីសាស្ត្រដែលមានកំហុស" ហើយអ្នកជំនាញមិនអព្យាក្រឹត[៣៧]។ ជាពិសេស សហមេធាវីការពារក្តីមិនបានបង្ហាញពីមូលហេតុ ដែលពួកគេមិនអាចលើកឡើងអំពីការព្រួយបារម្ភរបស់ខ្លួនអំពីវិធីសាស្ត្រនៃដីកាសម្រេច ឬអំពីកង្វះអព្យាក្រឹតភាពរបស់អ្នកជំនាញ បន្ទាប់ពីការចេញដីកានោះទេ។

២៤. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងត្រឹមត្រូវ ដែលសហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា សំណើរបស់សហមេធាវីការពារក្តីសុំឱ្យចាត់តាំងអ្នកជំនាញថ្មី ដែលមានប្រវត្តិការងារខាង[redacted]ដើម្បីធ្វើការស្រាវជ្រាវដើមនោះត្រូវបានដាក់យឺតពេលពេកក្នុងដំណាក់កាលនៃកិច្ចស៊ើបអង្កេត។ អង្គបុរេជំនុំជម្រះក៏កត់សំគាល់ឃើញផងដែរថា នៅក្នុងកថាខណ្ឌទី៨ នៃដីកាសម្រេចនោះ សហចៅក្រមស៊ើបអង្កេតបានផ្តល់សំអាងហេតុគ្រប់គ្រាន់សំរាប់គាំទ្រដល់សេចក្តីសម្រេចរបស់ខ្លួន ក្នុងការមិនរៀបចំឱ្យមានកិច្ចស៊ើបសួរខាង[redacted]តាមគំនិតផ្តួចផ្តើមរបស់ខ្លួន។

២៥. សហមេធាវីការពារក្តីក៏បានជំទាស់តវ៉ាផងដែរថា ការខកខានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការមិនបានស៊ើបអង្កេតដើម្បីរកឱ្យឃើញថា អ្នកជំនាញបានអនុវត្តតួនាទីដោយអនាគតិបានត្រឹមកម្រិតណានោះ បង្កើតបានជាការបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន[៣៨]។ សហមេធាវីការពារក្តីបានយោងទៅកថាខណ្ឌទី១៥ នៃដីកាសម្រេច ហើយបានលើកឡើងថា សេចក្តីសន្និដ្ឋានពីមុនរបស់សហចៅក្រមស៊ើបអង្កេត លើបញ្ហាអនាគតិភាពរបស់អ្នកជំនាញ គឺពាក់ព័ន្ធតែនឹងការចោទប្រកាន់របស់លោក អៀង សារី ទៅលើការងារពីមុនរបស់បណ្ឌិត Tabeau ជាមួយការិយាល័យរដ្ឋអាជ្ញានៅតុលាការ ICTY ប៉ុន្តែ សំណើសុំទីម្តៃប្រាំមួយ "ផ្អែកទៅលើការវាយតម្លៃរបាយការណ៍អ្នកជំនាញខ្លួនឯង ដែលភាពលំអៀងដោយសារតែស្ថាប័នជាទូទៅរបស់បណ្ឌិត Tabeau បានបង្ហាញឱ្យឃើញយ៉ាងច្បាស់[៣៩] ហើយបានតវ៉ាថា ដីការបស់សហចៅក្រមស៊ើបអង្កេតមិនបាន

---

[៣៧] សំណើទី២៦។

[៣៨] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ២២ ដល់ ២៤។

[៣៩] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ២៣។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00543822



ដោះស្រាយបញ្ហាដែលលើកឡើងនេះទេ។

២៦. ពាក់ព័ន្ធនឹងបញ្ហានេះដែរ អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានផ្តល់សំអាងហេតុគ្រប់គ្រាន់នៅក្នុងដីការបស់ខ្លួន។ សហចៅក្រមស៊ើបអង្កេតបានពន្យល់យ៉ាងល្អិតល្អន់អំពីវិធីដែលពួកគាត់ពិនិត្យលើវិធីអ្នកជំនាញបានយោងទៅប្រភពផ្សេងៗ ហើយក៏បានបញ្ជាក់ផងដែរថា "របាយការណ៍អ្នកជំនាញមិនភ្ជាប់កាតព្វកិច្ចមកលើចៅក្រមទេ" ហើយ "ក្នុងករណីដែលមានដីកាបញ្ជូនជនត្រូវចោទ ទៅជំនុំជម្រះ...គេនៅតែអាចកោះហៅអ្នកជំនាញឱ្យមកផ្តល់ភស្តុតាង និងសួរដេញដោលតទល់គ្នា អំពីបញ្ហាបច្ចេកទេសបានដដែលទេ"[៤០]។

២៧. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា ដើម្បីតវ៉ាជំទាស់នឹងរបាយការណ៍របស់អ្នកជំនាញ សហមេធាវីការពារក្តីបានចោទប្រកាន់នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា អ្នកជំនាញគ្មានអនាគតិភាព។ បញ្ហាទីមួយ ប្រសិនបើសហមេធាវីការពារក្តីបានព្រួយបារម្ភអំពីអនាគតិភាពរបស់អ្នកជំនាញ ដូចបានបញ្ជាក់ខាងលើ ពេលវេលាដែលត្រូវយកបញ្ហានេះមកតវ៉ា គឺនៅពេលដែលសហចៅក្រមស៊ើបអង្កេតបានចេញដីកាចាត់តាំងអ្នកជំនាញទាំងនោះមកម្ល៉េះ[៤១]។ បញ្ហាទីពីរ បញ្ហាអនាគតិភាពរបស់អ្នកជំនាញ ពាក់ព័ន្ធនឹងតម្លៃនៃរបាយការណ៍របស់អ្នកជំនាញ ហើយដូចដែលសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ក្នុងដីការបស់ខ្លួនថា របាយការណ៍អ្នកជំនាញមិនភ្ជាប់កាតព្វកិច្ចមកលើចៅក្រមទេ។ អង្គបុរេជំនុំជម្រះក៏កត់សំគាល់ឃើញផងដែរថា តាមមូលហេតុដែលបានអះអាង ការតវ៉ានេះមិនទាន់ដល់ពេលទេ ពីព្រោះសហចៅក្រមស៊ើបអង្កេតមិនទាន់បានចេញសេចក្តីសម្រេច ឬដីកាសម្រេចដែលបង្ហាញពីតម្លៃដែលសហចៅក្រមស៊ើបអង្កេតផ្តល់ចំពោះរបាយការណ៍នោះនៅឡើយទេ។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា គេនៅតែអាចកោះហៅអ្នកជំនាញឱ្យមកផ្តល់ភស្តុតាង និងសួរដេញដោលតទល់គ្នាបានក្នុងអំឡុងពេលបើកសវនាការ។

---

[៤០] ដីកាសម្រេច, កថាខណ្ឌ១៣ និង១៤។

[៤១] សូមមើល កថាខណ្ឌ២៣ ខាងលើ។

00543823



២៨. អង្គបុរេជំនុំជម្រះយល់ឃើញថា ការព្យាយាមចោទប្រកាន់អំពីអនាគតិរបស់អ្នកជំនាញ ដោយយកទំនាក់ទំនងការងារពីមុនមកធ្វើជាមូលហេតុ ដែលមិនទាក់ទងផ្ទាល់ទៅនឹងរឿងក្តីនេះជាមួយសហចៅក្រមស៊ើបអង្កេត បង្ហាញពីការទាញសន្និដ្ឋានទូទៅផ្អែកលើករណីមួយចំនួនតូចប៉ុណ្ណោះ និងគ្មានមូលដ្ឋានគ្រប់គ្រាន់ទេ ហើយមិនបានបំពេញតាមលក្ខខណ្ឌអប្បបរមានៃភាពជាក់លាក់គ្រប់គ្រាន់ ដើម្បីឱ្យអង្គបុរេជំនុំជម្រះអាចជឿជាក់លើការអះអាងនេះបានទេ។ សហមេធាវីការពារក្តីបានប្រកាន់យកការចោទប្រកាន់របស់លោក អៀង សារី ស្តីពីអនាគតិភាពរបស់អ្នកជំនាញ ដែល ស.ច.ស និង អង្គបុរេជំនុំជម្រះបានបដិសេធចោលរួចមកហើយនោះ[៤២]។

២៩. សហមេធាវីការពារក្តីបានលើកឡើងថា លោក ចឺ ឃាម ជាអ្នកជំនាញខ្មែរដែលត្រូវបានចាត់តាំងមានមុខតំណែងនៅក្នុងក្រសួងផែនការនៃរាជរដ្ឋាភិបាលកម្ពុជា គឺជាមូលហេតុនៃការព្រួយបារម្ភ ហើយបានអះអាងថា ការខកខានរបស់សហចៅក្រមស៊ើបអង្កេត ដោយមិនបានទទួលស្គាល់បញ្ហានៃភាពមិនឯករាជ្យរបស់មន្ត្រីរាជការពីអាជ្ញាធររដ្ឋាភិបាល គឺជា"ការគួរឱ្យខកចិត្ត"[៤៣]។ ដូចដែលសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ក្នុងដីការបស់ខ្លួន អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា ការព្រួយបារម្ភរបស់សហមេធាវីការពារក្តី គ្មានមូលហេតុគ្រប់គ្រាន់ គ្មានភស្តុតាងជាក់លាក់ដែលពាក់ព័ន្ធនឹងអ្នកជំនាញ ឬរឿងក្តីនេះនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតឡើយ។

៣០. សំអាងហេតុដូចបានបញ្ជាក់ខាងលើ គឺជាសំអាងហេតុគាំទ្រសាលដីកាអង្គបុរេជំនុំជម្រះបានសម្រេចលើបណ្តឹងឧទ្ធរណ៍ ដែលបានប្រកាសនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កន្លងមកនេះ។

---

[៤២] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ដែល បដិសេធសំណើរបស់គាត់សុំតែងតាំងអ្នកជំនាញ[redacted]បន្ថែមមួយរូប ដើម្បីធ្វើការពិនិត្យឡើងវិញទៅលើខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញ ដែលបានដាក់ជូនដោយលោកស្រី Ewa TABEAU និងលោក ចឺ ឃាម ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០ D140/9/5។ ដីកាសម្រេចលើសំណើសុំអ្នកជំនាញ[redacted]មួយរូបបន្ថែមទៀត ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ D140/3 និងសំណើរបស់ អៀង សារី សុំឱ្យចាត់តាំងអ្នកជំនាញ[redacted]មួយរូបបន្ថែមទៀត ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ D140/8។

[៤៣] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ២៤ ដោយយោងដីកាសម្រេច, កថាខណ្ឌ១៦ និងសំណើទី២៦, កថាខណ្ឌ៣៥។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០

អង្គបុរេជំនុំជម្រះ ប្រធាន

Rowan DOWNING នំយ ថុល Catherine MARCHI-UHEL ហួត វុទ្ធី ប្រាក់ គីមសាន